# ស្រុកខ្មែរ ស្រុកខ្ញុំ

១. ស្រុកខ្មែរស្រុកខ្ញុំ ជាឋានសុខុម ពុំមានអ្វីផ្ទឹម
ទេសភាពទាំងឡាយ ស្រស់ស្រាយញញឹម ដូចព្រឹកព្រលឹម
មិនចាញ់ព្រះសូរ្យ ។

២. ស្រុកខ្មែរស្រុកខ្ញុំ ជាឋានមនោរម្យ ឧត្តមបវរ
ដូចទេពនិមិត្រ ពិតជាស្រស់ល្អ ដែលវិចិត្រករ
មិនអាចឆ្នៃបាន ។

៣. ស្រុកខ្មែរស្រុកខ្ញុំ ដូចផ្កាក្រពុំ ក្នុងសួនឧទ្យាន
គន្ធាក្រអូប ក្លិនស្រូបវិញ្ញាណ សព្វសាយដល់ឋាន
ដែលបានប្រាថ្នា ។

៤. ស្រុកខ្មែរស្រុកខ្ញុំ ស្រស់ស្រីក្រមុំ សមរិកព្រហ្មចារ
សំដីទន់ភ្លន់ គន់គួរចេទនា ជាទីស្នេហា
ភូមិរាគ្រប់គ្នា ។

៥. ស្រុកខ្មែរស្រុកខ្ញុំ ទំនៀមជួបជុំ បងប្អូនមីងមាន
ខួបខែចូលឆ្នាំ បុណ្យភ្ជុំនាំគ្នា រាំច្រៀងលៀងជា
ភោគផលអាហារ ។

៦. ឥឡូវឃ្លាតហើយ ស្រុកខ្មែរខ្ញុំអើយ ខ្ញុំសែនសោកា
នឹកអ្នករាល់ថ្ងៃ ដោយក្ដីស្នេហា ចិត្តចងចេទនា
ចង់ឆាប់វិលវៃ ។

៧. ឥឡូវឃ្លាយហើយ ស្រុកខ្មែរខ្ញុំអើយ ខ្ញុំសែនអាល័យ
គ្រាដែលអ្នកធ្លាប់ ផ្ដល់សុខប្រពៃ ឥឡូវឃ្លាតឆ្ងាយ
ឯនាយសមុទ្រ ។

៨. ឥឡូវឃ្លាតហើយ ស្រុកខ្មែរខ្ញុំអើយ ខ្ញុំសែនតក់ស្លុត
ពេលលឺថាអ្នក ត្រូវគេសំឡុត គំរាមប្រយុទ្ធ
បង្ខំរណប ។

---

៩. ឱខេមរារដ្ឋ នៃរាជ្យបុរី ពូជពង្សធ្លាប់ល្បី មិនដែលខ្លាចខ្លប
ស៊ូប្តូរហូរឈាម មិនដែលរណប មិនដែលបាក់ខ្លប ចាញ់កលសត្រូវ ។

១០. ពូជពង្សខ្មែររស់ ព្រោះដៃប្រយុទ្ធ មិនដែលតក់ស្លុត រឿងត្រជាក់ក្តៅ
ទោះបីមរណា ចារឈ្មោះទុកនៅ ផ្តាំដល់កូនចៅ តរគ្រាប់ជំនាន់ ។

១១. បើមានកំណើត កើតជាកូនខ្មែរ ត្រូវចេះគិតកែ រឿងរ៉ាវជាប់កុន
មិនត្រូវសំកុក ដេកផ្សងចាំបុណ្យ ពិសោធអ្នកមុន ទុកអោយអ្នកក្រោយ ។

១២. ដូនតាថ្លាថ្លែង សំដែងប្រដៅ ដាស់ដល់កូនចៅ ថាពៅកុំអោយ
បរទេសឈ្លានពាន លៀនលួចមុខក្រោយ ដីតាចែកអោយ រក្សាអោយថ្កាន ។

១៣. ដើមត្នោតដំណាង សំអាងជាកេរ្តិ៍ មរត្តកជាតិខ្មែរ តាំងពីបុរាណ
ប្រាង្គប្រាសាទថ្ម ល្អលើសការស្មាន ថ្លៃឥតប្រមាណ លើឋានលោកិយ ។

១៤. ក្បូរក្បាច់ចំលាក់ មាន លឹម លាន លោត គន់គួរអោយកោត សរសើរថ្វីដៃ
ដ៏សែនប្រសព្វ អស្ចារ្យពេកក្រៃ គប្បីបុត្រថ្លៃ រក្សាអោយជា ។

១៥. បឹងបូរទំនាប ទាបខ្ពស់ជ្រោះភ្នំ ព្រឹក្សព្រៃស្តុកស្តម ម្រឹគីម្រឹគា
សម្បត្តិសម្បូរ ពេញពោរកម្ពុជា ច្រើនឥតគណនា លើដីខេមរា ។

១៦. ស្រុកខ្មែរស្រុកខ្ញុំ ក្រពុំជាប់ចិត្ត ខ្មែរអើយអាណិត គិតពិចារណា
អាសូរដល់ឈាម ជីដូនជីតា ដែលបង់សង្ខា ព្រោះការពារស្រុក ។

១៧. ស្រុកខ្មែរស្រុកខ្ញុំ ក៏ជាស្រុកអ្នក សូមកុំបែកបាក់ រក្សាក្តីសុខ
មហាគ្រួសារខ្មែរ ត្រូវចេះរួមទុក្ខ រំលែកសាងសុខ ដល់ខ្មែរគ្រប់គ្នា. . . ។

**សួន សេរីរដ្ឋា**

ព្រលានយន្តហោះសឹង្ហបុរី រាត្រីថ្ងៃទី២៣ កុម្ភៈ ២០០៦